**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងព្រះសីហនុ**
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ២៤៨ ចុះថ្ងៃទី ២៧
ខែ សីហា ឆ្នាំ ២០០២
<u>សាលក្រម</u>
លេខ ៣៨ ចុះថ្ងៃទី ០២
ខែ មិថុនា ឆ្នាំ ២០០៤

សាលក្រមនេះបានចូលជាស្ថាពរហើយ ។
ក្រុងព្រះសីហនុ,ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
ក្រឡាបញ្ជី [redacted]

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងព្រះសីហនុ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៤៨ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០២ ដែលមានជនជាប់ ចោទឈ្មោះ **ចា សត** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ កើតនៅភូមិ ១ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះ **ចា ខ** (រ) ម្តាយឈ្មោះ **ញ ស** (រ) នៅលីវ ទោសពីមុន *គ្មាន* សព្វថ្ងៃនៅក្រៅឃុំ ។

១-ឈ្មោះ **គ សន** ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ រស់នៅភូមិ ៤ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះ **ឌ គ** (រ) ម្តាយឈ្មោះ **ច អ** (រ) នៅលីវ ទោសពីមុន *គ្មាន* សព្វថ្ងៃគេចខ្លួន ។

២-ឈ្មោះ **ម អរ** ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ ទីលំនៅភូមិ ១ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះ **ម ស** (រ) ម្តាយឈ្មោះ **ឈ មណា** (រ) នៅលីវ ទោសពីមុន *គ្មាន* សព្វថ្ងៃគេចខ្លួន ។

៣-ឈ្មោះ **ឧ សម** ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ រស់នៅភូមិ ១ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះ **ឧ សម** (រ) ម្តាយឈ្មោះ **ឡ សន** (រ) នៅលីវ ទោសពីមុន *គ្មាន* សព្វថ្ងៃគេចខ្លួន ។

៤-ឈ្មោះ **ម សរ** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ រស់នៅភូមិ១ សង្កាត់២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ឪពុកឈ្មោះ **អ មសរ** (រ) ម្តាយឈ្មោះ **ភ ស** (រ) នៅលីវ ទោសពីមុន *គ្មាន* សព្វថ្ងៃគេចខ្លួន ។

ត្រូវចោទពី "ប្លន់ចោរកម្ម និង សមគំនិតក្នុងអំពើចោរកម្ម" ប្រព្រឹត្តនៅភូមិ ១ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២

បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោស តាមមាត្រា ៤៣ និង មាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-លោក ៖ **ខណះ** តំណាងអោយមន្ទីរវប្បធម៌ក្រុងព្រះសីហនុ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៩២ ដ.ស.ព ០៤ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៤ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៤១៤ ត.ព ០៤ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

**ដំណើររឿងមានដូចតទៅ :**

កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០២ វេលាម៉ោង ១០ និង ៣០នាទីយប់ ឈ្មោះ **ឃ សគ** និង បក្ខពួកឈ្មោះ **ទរ, ម, ន, រ, ឥ** បានលួចគាស់បង្អួចកញ្ចក់ចំនួន ២ ផ្ទាំងរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ក្រុងព្រះសីហនុ រួចយកទៅលាក់ទុកនៅជិតតារាងបាល់ទះ ក្នុងមហោស្រព ក្រុងព្រះសីហនុ ។ លុះដល់ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ វេលាម៉ោង ១៩ និង ៣០នាទី ពួកវាបានអោយឈ្មោះ **ឃ សគ** ហៅ **គ** និង ឈ្មោះ **៖** យកបង្អួចដែលលួចបាននោះទៅលក់ ប៉ុន្តែត្រូវសមត្ថកិច្ចចាប់ខ្លួនបានឈ្មោះ **ឃ សគ** ឯឈ្មោះ **៖** បានគេចខ្លួនបាត់ ។ បន្ទាប់មកសមត្ថកិច្ចបានបញ្ជូនខ្លួនឈ្មោះ **ឃ សគ** មកតុលាការតែម្តងទៅ ។

**នារពលសខនាការ**

-តាមការអានចម្លើយឈ្មោះ **ឃ សគ** ជាជនជាប់ចោទឆ្លើយថា : កាលពីយប់ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០២ បក្សពួកដោយមានឈ្មោះ **ទរ, ម, ន, ឥ** និង **៖** បានលួចគាស់បង្អួចកញ្ចក់ចំនួន ០២ផ្ទាំង រួចយកទៅលាក់ទុកនៅក្នុងមហោស្រពជិតតារាងបាល់ទះ លុះស្អែកឡើងវេលាម៉ោង ១៩ និង ៣០នាទីយប់ ខ្លួន និង ឈ្មោះ **៖** ក៏ចូលទៅយកបង្អួចកញ្ចក់ដែលលាក់ទុកនោះបំរុងយកទៅលក់ ប៉ុន្តែត្រូវសមត្ថកិច្ចចាប់ខ្លួន ឯឈ្មោះ ៖ រត់រួច និង បញ្ជូនខ្លួនមកតុលាការតែម្តង ។

-ឈ្មោះ ៖ **ខណះ** ជាតំណាងមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ក្រុងព្រះសីហនុ បានឆ្លើយថា : កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០២ មានក្រុមចោរមួយក្រុម បានគាស់ទ្វារបន្ទប់ប្រធានមន្ទីរវប្បធម៌ យកកង្ហារបញ្ឈរចំនួន ១, អំពូលភ្លើង ០១កាំបិតចុងស្រួច ០១ ។ គាស់លើកទី ២ នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០២ គឺបាត់កង្ហារ បញ្ឈរចំនួន ០១, គងបុរាណចំនួន ០២, ប៊ីដុងទឹក ០២, ធុងស្ពាន់ ០១, កែវទឹក ០៩ និង ព្រមទាំងរុះរើឯកសារ ក្នុងបន្ទប់ទៀតផង ។ លុះនៅថ្ងៃទី ២៤ ខែ សីហា **ឆ្នាំ ២០០២** យើងបានតាមដានសកម្មភាពក្រុមចោររហូតដល់យប់ និង ចាប់បានរួមទាំងវត្ថុតាងកញ្ចក់ចំនួន ០២ផ្ទាំង ។ ក្នុងរឿងនេះខ្លួនសំណូមពរអោយតុលាការធ្វើការផ្តន្ទាទោសជនល្មើស តាមច្បាប់ និង សំណង ជម្ងឺចិត្តខ្លួនមិនទាមទារឡើយ ។

-តាមការអានចម្លើយរបស់លោក **ព សខន** អនុប្រធានការិយាល័យព្រហ្មទណ្ឌកិតស្រាលបញ្ជាក់ថា : ឈ្មោះ **ឃ សគ** នេះ គ្រាន់តែជាអ្នកយកផ្ទាំងកញ្ចក់បង្អួច ០២ផ្ទាំងទៅលក់តែប៉ុណ្ណោះ គឺវាមិនបានចូលរួមលួចផ្ទាំងកញ្ចក់ និងសម្ភារៈផ្សេងទៀតដូចជា គង, អំភ្លី, កង្ហារ នោះទេ ហើយចំពោះជនល្មើសដែលបានលួចផ្ទាល់នោះមានឈ្មោះ ៖, ម, ឥ, ទរ និង **ន** ហើយចំពោះសាវតាជាតិរបស់ពួកវា សមត្ថកិច្ចកំពុងស្រាវជ្រាវបន្ត ។ គ្រាន់តែឈ្មោះ **ឃ សគ** យកកញ្ចក់០២ផ្ទាំងនោះទៅលក់ ប៉ុន្តែមិនទាន់លក់បានផងត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន ហើយបញ្ជូនមកតុលាការផងដែរ ។

-តំណាងអយ្យការបានធ្វើការសន្និដ្ឋានទោសថា : មានពិរុទ្ធភាពលើឈ្មោះ **ហ សត**, **គ សន**, **ប តរ**, **ឧ សម**, **ទ សរ** ពីបទចោរកម្ម និង សមគំនិតក្នុងអំពើចោរកម្ម ប្រព្រឹត្តនៅភូមិ ១ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្ដន្ទាទោស តាម មាត្រា ៤៣ និង មាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ក្រោយពីបានស្ដាប់ការអានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹង

-ក្រោយពីបានស្ដាប់ការអានចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

## <u>តុលាការខេត្តក្រុងព្រះសីហនុ</u>

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>យល់ឃើញថា</u>

-កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០២ ពិតជាមានក្រុមចោរមួយក្រុមបានគាស់បង្អួចកញ្ចក់ចំនួន ០២ផ្ទាំង របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈក្រុងព្រះសីហនុ យកទៅលាក់ទុកនៅក្នុងបរិវេណមហោស្រពក្បែរតារាងបាល់ទះ ដោយមានការសហការជាមួយសមត្ថកិច្ចបានល្អ លុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ ទើបចាប់ខ្លួនជនល្មើសបានម្នាក់ នៅខណៈពេលដែលជនល្មើសបំរុងយកផ្ទាំងកញ្ចក់ចេញពីកន្លែងលាក់យកទៅលក់ ។

-តាមចម្លើយសារភាពរបស់ឈ្មោះ **ហ សត** បានបញ្ជាក់ថា បក្ខពួកខ្លួនពិតជាបានលួចគាស់កញ្ចក់បង្អួចចំនួន ០២ផ្ទាំងរបស់មន្ទីរវប្បធម៌ក្រុងព្រះសីហនុប្រាកដមែន ប៉ុន្តែចំពោះសកម្មភាពលួចមុនៗ ខ្លួនមិនបានចូលរួមប្រព្រឹត្តទេ ។

-តាមការអានដីកាចាប់ខ្លួនឈ្មោះ **គ សន** លេខ ៥៤ ដចខ ០៤ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៤ របស់ ចៅក្រមស៊ើបសួរ ។

-តាមការអានដីកាចាប់ខ្លួនឈ្មោះ **ប តរ** លេខ ៥៥ ដចខ ០៤ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៤ របស់ ចៅក្រមស៊ើបសួរ ។

-តាមការអានដីកាចាប់ខ្លួនឈ្មោះ **ឧ សម** លេខ ៥៦ ដចខ ០៤ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៤ របស់ ចៅក្រមស៊ើបសួរ ។

-តាមការអានដីកាចាប់ខ្លួនឈ្មោះ **ទ សរ** លេខ ៥៧ ដចខ ០៤ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៤ របស់ ចៅក្រមស៊ើបសួរ ។

-ជនជាប់ចោទឈ្មោះ **ហ សត** ជាអនីតិជន មិនទាន់ចេះពិចារណាត្រឹមត្រូវ ត្រូវបានគេប្រើអោយទៅយក កញ្ចក់ ដើម្បីយកទៅលក់បានលុយចាយប៉ុណ្ណោះ ទោះបីខ្លួនមិនបានប្រព្រឹត្តផ្ទាល់ក៏ដោយ ក៏មានលក្ខណៈសមគំនិតដែរ ដោយឈ្មោះនេះដឹងច្បាស់ណាស់ថា កញ្ចក់ ០២ផ្ទាំង គឺបក្ខពួកខ្លួនជាអ្នកលួច តែឈ្មោះនេះមិនព្រមរាយការណ៍ជូន សមត្ថកិច្ច បែរជាឃុបឃិតជាមួយបក្ខពួក ដូច្នេះចាត់ទុកថា ជាអំពើសមគំនិតប្រព្រឹត្តអំពើល្មើសបំពានមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ហ សត** កន្លងមកត្រូវបានតុលាការក្រុងព្រះសីហនុ ឃុំខ្លួននៅពន្ធនាគារក្រុងមួយរយៈហើយក៏បាន អនុញ្ញាតអោយនៅក្រៅឃុំបណ្ដោះអាសន្ន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ហ សត, គ សន, ប គរ, ទ សរ** និង **ឧ សម** ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិ ១ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២ ។

**<u>ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ</u>**

**<u>សំរេច</u> :**

**<u>ផ្តន្ទាទោស</u> :**

១-ឈ្មោះ **គ សន** ភេទប្រុស អាយុ ២៤ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ( មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន និង យកមកឃុំខ្លួននៅពន្ធនាគារក្រុងព្រះសីហនុ ក្រោយពេលសាលក្រមនេះចូលជាស្ថាពរ ។

២-ឈ្មោះ **ទ សរ** ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ( មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន និង យកមកឃុំខ្លួននៅពន្ធនាគារក្រុងព្រះសីហនុ ក្រោយពេលសាលក្រមនេះចូលជាស្ថាពរ ។

៣-ឈ្មោះ **ឧ សម** ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ( មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន និង យកមកឃុំខ្លួននៅពន្ធនាគារក្រុងព្រះសីហនុ ក្រោយពេលសាលក្រមនេះចូលជាស្ថាពរ ។

៤-ឈ្មោះ **ប គរ** ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ( មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន និង យកមកឃុំខ្លួននៅពន្ធនាគារក្រុងព្រះសីហនុ ក្រោយពេលសាលក្រមនេះចូលជាស្ថាពរ ។

ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិ ១ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥-ឈ្មោះ **ហ សត** ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ខែ ( ប្រាំមួយខែ) គិតពីថ្ងៃចាប់ខ្លួនបាន និង យកមកឃុំខ្លួននៅពន្ធនាគារក្រុងព្រះសីហនុ ក្រោយពេលសាលក្រមនេះចូលជាស្ថាពរ ។

ពីបទសមគំនិតក្នុងអំពើចោរកម្ម ប្រព្រឹត្តនៅភូមិ ១ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹង កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងអំឡុងច្បាប់ ។

**ក្រឡាបញ្ជី**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]